រដ្ឋបាលព្រៃឈើ

# ឈើនៅកម្ពុជា
# Timbers in Cambodia

នាយកដ្ឋានឧស្សាហកម្មព្រៃឈើ
និង សហប្រតិបត្តិការអន្តរជាតិ
ឆ្នាំ២០២១
បោះពុម្ពលើកទី១

# អារម្ភកថា

ប្រទេសកម្ពុជានិយមការប្រើប្រាស់ឈើតាំងពីបរមបុរាណយើងមក ពិសេសការសាងសង់ផ្ទះ តុ ទូ ជាដើម ដោយសារភាពសម្បូរព្រៃឈើនៅកម្ពុជា។ បច្ចុប្បន្ននេះ តម្រូវការប្រើប្រាស់ឈើនៅតែមានកំណើនខ្លាំង និងមានលក្ខណៈកាន់តែទំនើប ប្រកបដោយការច្នៃប្រឌិតកាន់តែខ្ពស់ ហើយបានក្លាយទៅជាមុខជំនួញមានលក្ខណៈជាពាណិជ្ជកម្មធំមួយ។

ផ្អែកលើមូលដ្ឋានបទពិសោធន៍ដែលធ្លាប់បានប្រើប្រាស់កន្លងមក មនុស្សបានបែងចែកឈើទៅជាច្រើនប្រភេទផ្សេងគ្នា អាស្រ័យទៅតាមភាពធន់របស់ឈើ សោភ័ណ្ឌភាពសាច់ឈើ ភាពសម្បូរណ៍នៅក្នុងធម្មជាតិ តម្រូវការលើទីផ្សារក្នុងស្រុក ក្រៅស្រុក និងទីផ្សារអន្តរជាតិ។ នៅប្រទេសកម្ពុជាយើង ក្រៅពីតម្រូវការប្រើប្រាស់នៅក្នុងស្រុក គេបានឃើញមានការធ្វើពាណិជ្ជកម្មឈើតាំងពីសម័យបុរាណមកម្ល៉េះ ហើយជាពិសេស បុព្វបុរសយើងមានទេពកោសល្យក្នុងការប្រើប្រាស់ឈើទៅតាមប្រភេទនីមួយៗ ជាអាទ៍ដូចជាមានពាក្យចាស់ថា គគីរនិងទឹក ធ្វឹកនិងដី ឈើវៀចអោយប្រើធ្វើកង់ ឈើត្រង់អោយប្រើធ្វើកាំឯឈើសាំញ៉ាំអោយធ្វើអុសដុត កុំពត់ឈើស្រទ្បៀ កុំប្រដៅមនុស្សខូច...។ល។

តាមប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឈើនៅក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ថ្នាក់ជាឈើប្រណិត ឈើលេខ១ ឈើលេខ២ ឈើលេខ៣ និងប្រភេទឈើក្រៅលំដាប់ថ្នាក់។ ការចាត់ថ្នាក់ឈើទៅតាមប្រភេទខាងលើនេះ គឺសំដៅធ្វើឲ្យមានភាពងាយស្រួលដល់ការយល់ដឹងអំពីគុណភាពនៃប្រភេទឈើដែលមានប្រភពក្នុងព្រៃធម្មជាតិរបស់យើង។

ការចងក្រងសៀវភៅ **ឈើនៅកម្ពុជា** នេះឡើង គឺក្នុងគោលបំណងបង្ហាញឲ្យស្គាល់ពីប្រភេទឈើចំនួន ១២២ប្រភេទ រួមទាំងឈ្មោះវិទ្យាសាស្ត្រ ឈ្មោះពាណិជ្ជកម្ម អំបូរ ចំណាត់ថ្នាក់ ដង់ស៊ីតេ(កម្រិតសំណើមបរិយាកាស) ពណ៌សាច់ឈើ និងការប្រើប្រាស់តាមប្រភេទឈើ ដែលជាគុណប្រយោជន៍ដល់អ្នកស្រាវជ្រាវ និងអ្នកស្រលាញ់ចូលចិត្តឈើគ្រប់រូប រួមទាំងពាណិជ្ជករផងដែរ។

រដ្ឋបាលព្រៃឈើសូមស្វាគមន៍ចំពោះការផ្តល់យោបល់ និងការកែតម្រូវបន្ថែម សម្រាប់បង្កើនគុណភាពលើការបោះពុម្ពលើកទី២។

រដ្ឋបាលព្រៃឈើ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលតែងតែជំរុញ និងគាំទ្រលើការស្រាវជ្រាវ និងបោះពុម្ពឯកសារនានាសម្រាប់ជាមូលដ្ឋានសិក្សារបស់មន្ត្រីរាជការ និងប្រជាពលរដ្ឋ។

រដ្ឋបាលព្រៃឈើ សូមថ្លែងអំណរគុណ ជូនចំពោះថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើទាំងថ្នាក់កណ្តាល និងតាមខេត្ត ជាពិសេសនាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់រួមមាន អាជីវករ សិប្បករ ពាណិជ្ជករ និងសហគមន៍មូលដ្ឋាន ដែលបានចូលរួមយ៉ាងសកម្មជួយដល់ក្រុមការងារចុះស្រាវជ្រាវ រហូតដល់បោះពុម្ពជាសៀវភៅនេះលើកទីមួយដោយជោគជ័យ និងសូមថ្លែងអំណរគុណចំពោះ KOREA MEKONG FOREST COOPERATION CENTER (KMFCC) ដែលបានឧបត្ថម្ភបោះពុម្ពសៀវភៅនេះ។

**បណ្ឌិត កែវ អូម៉ាលីស្ស**

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា

ប្រធានរដ្ឋបាលព្រៃឈើ

# មាតិកា

AIDOC
Code: 262-015
Date:
Donated by:

ទំព័រ

**អារម្ភកថា** ........................................ i

**ប្រភេទឈើប្រណិត**

១. ក្រញូង ........................................ ១
២. ក្រញូងស្វា ........................................ ២
៣. គ្រើល ........................................ ៣
៤. ច្រេស ........................................ ៤
៥. ឈើខ្មៅ ........................................ ៥
៦. តាត្រាវ ........................................ ៦
៧. ត្រយឹង ........................................ ៧
៨. ធ្នង់ ........................................ ៨
៩. នាងនួន ឬ លាំង ........................................ ៩
១០. បេង ........................................ ១០
១១. ហ៊ុនដាង ឬ ម្រះព្រៅភ្នំ ........................................ ១១
១២. ហែសាន ឬ ចាន់ស ........................................ ១២
១៣. អង្កត់ខ្មៅ ........................................ ១៣
១៤. អង្គាញ់ ........................................ ១៤

**ប្រភេទឈើលេខ១**

១៥. កកោះ ........................................ ១៥
១៦. កែស ........................................ ១៦
១៧. ក្រឡាញ់ ........................................ ១៧
១៨. គគីរថ្ម ........................................ ១៨
១៩. គគីរម្សៅ ........................................ ១៩

២០. ល្បឺក ........................................................ ២០
២១. ដូនចែម ឬ បីសន្លឹក ........................................................ ២១
២២. ត្រសេក ឬ ត្រាំកង់ ........................................................ ២២
២៣. បូសនាគ ........................................................ ២៣
២៤. បេឡឺយ ........................................................ ២៤
២៥. ផ្ចឹក ........................................................ ២៥
២៦. ពពូល ឬ ភ្នែល ........................................................ ២៦
២៧. ពពេល ........................................................ ២៧
២៨. រាំងភ្នំ ........................................................ ២៨
២៩. វល្លិ៍យោង ........................................................ ២៩
៣០. សុក្រម ........................................................ ៣០
៣១. ស្រឡៅ ឬ ឥន្ទនេល ........................................................ ៣១
៣២. សំព័រ ........................................................ ៣២

## ប្រភេទឈើលេខ២

៣៣. ខ្លុង ........................................................ ៣៣
៣៤. ខ្វាវ ........................................................ ៣៤
៣៥. គគីរខ្សាច់ ........................................................ ៣៥
៣៦. ច្រម៉ាស់ ........................................................ ៣៦
៣៧. ឆាំឆា ........................................................ ៣៧
៣៨. ជីរចុង ........................................................ ៣៨
៣៩. ឈើទាលធ្ង ........................................................ ៣៩
៤០. ឈើទាលបង្គួយ ឬ ឈើទាលនាងដែង ........................................................ ៤០
៤១. ឈើទាលប្រេង ........................................................ ៤១
៤២. ត្បែង ........................................................ ៤២
៤៣. ត្រឡាត់ ........................................................ ៤៣

៤៤. ត្រាច ........................................ ៤៤
៤៥. ផ្ដៀក ........................................ ៤៥
៤៦. លំបោ ........................................ ៤៦
៤៧. ស្រគុំ ........................................ ៤៧
៤៨. ស្រល់ ........................................ ៤៨
៤៩. ស្រ្គលក្រហម ........................................ ៤៩
៥០. ស្រ្គលស ........................................ ៥០

## ប្រភេទឈើលេខ៣

៥១. កណ្ដោល ........................................ ៥១
៥២. កោងកាង ........................................ ៥២
៥៣. កំពីងរាជ ........................................ ៥៣
៥៤. ក្ដុល ........................................ ៥៤
៥៥. ក្របៅ ........................................ ៥៥
៥៦. ក្រាយស ........................................ ៥៦
៥៧. ចង្អូរត្នោត ........................................ ៥៧
៥៨. ចន្ទន៍ក្រស្នា ........................................ ៥៨
៥៩. ចេកទុំ ........................................ ៥៩
៦០. ត្រប់ទុំ ........................................ ៦០
៦១. ទ្រមូង ........................................ ៦១
៦២. ធ្លូក ........................................ ៦២
៦៣. បង្គៅ ........................................ ៦៣
៦៤. ប្រាំដំឡឹង ........................................ ៦៤
៦៥. ផ្ដុង ........................................ ៦៥
៦៦. ព្រីង ........................................ ៦៦
៦៧. ព្រ្ហូស ........................................ ៦៧

៦៨. ល្បៀង ........ ៦៨
៦៩. ស្មាក្របី ........ ៦៩
៧០. ស្មាច់ ........ ៧០
៧១. ស្វាយចំរៀង ........ ៧១
៧២. ស្វាយព្រៃ ........ ៧២

## ប្រភេទឈើក្រៅលំដាប់ថ្នាក់

៧៣. កន្ទួតព្រៃ ........ ៧៣
៧៤. ក្តុមគោក ........ ៧៤
៧៥. ខ្វាស ........ ៧៥
៧៦. ចាន់ ឬ ប៉ែន ........ ៧៦
៧៧. ចារ ........ ៧៧
៧៨. ចំបក់ ........ ៧៨
៧៩. ឆ្កែស្រែង ........ ៧៩
៨០. ញព្រៃ ........ ៨០
៨១. ត្របែកព្រៃ ........ ៨១
៨២. ទន្លាប់ព្រៃ ........ ៨២
៨៣. ទ្រាស ........ ៨៣
៨៤. ពង្រ ........ ៨៤
៨៥. ពោនស្វា ........ ៨៥
៨៦. ព្រះញ្ញៅ ........ ៨៦
៨៧. មៀនព្រៃ ........ ៨៧
៨៨. ម្កាក់ព្រៃ ........ ៨៨
៨៩. រមាំង ........ ៨៩
៩០. រយោង ........ ៩០
៩១. រលាយធំ ........ ៩១

៩២. រាជកុល ........ ៩២
៩៣. លាំងដៃធំ ........ ៩៣
៩៤. ល្បៀង ........ ៩៤
៩៥. វាយឧក ឬ អំបែងថែស ........ ៩៥
៩៦. ស័ក្បា ........ ៩៦
៩៧. ស្គុកស្គុរ ........ ៩៧
៩៨. ស្តៅ ........ ៩៨
៩៩. ស្នួល ........ ៩៩
១០០. ស្លង់ ........ ១០០
១០១. ឪឡោក ........ ១០១

## ប្រភេទឈើដាំ

១០២. កៅស៊ូ ........ ១០២
១០៣. ក្រទំុថេត ឬ ក្ទម្ពទេស ........ ១០៣
១០៤. ក្រសាំង ........ ១០៤
១០៥. គ្រាប់បែក ឬ គីនីន ........ ១០៥
១០៦. ខ្នុរ ........ ១០៦
១០៧. ត្នោត ........ ១០៧
១០៨. ប្រេងខ្យល់ ........ ១០៨
១០៩. ម៉ាក់ប្រាង ........ ១០៩
១១០. ម៉ៃសាក់ ........ ១១០
១១១. ស្វាយចន្ទី ........ ១១១
១១២. ស្វាយស្រុក ........ ១១២
១១៣. អាកាស្យាស្លឹកតូច ........ ១១៣
១១៤. អាកាស្យាស្លឹកធំ ........ ១១៤
១១៥. អំពិល ........ ១១៥

១១៦. អំពិលទឹកបារាំង ឬ ច័ន្ទគិរី ..................... ១១៦

## ប្រភេទឈើនាំចូល

១១៧. Chanfuta ..................... ១១៧
១១៨. Dark red maranti ..................... ១១៨
១១៩. Doussie ..................... ១១៩
១២០. Mussivi ..................... ១២០
១២១. Pau ferro ..................... ១២១
១២២. Umbila ..................... ១២២

# ប្រភេទឈើប្រណិត

# ១- ក្រញូង

- ឈ្មោះវិទ្យាសាស្ត្រ : *Dalbergia cochinchinensis* Pierre
- ឈ្មោះពាណិជ្ជកម្ម : Kranhung / Tulipwood / Siam rosewood
- អំបូរ : Leguminosae
- ចំណាត់ថ្នាក់ : ប្រភេទឈើប្រណិត
- ដង់ស៊ីតេ : ១០០០-១២០០ គ.ក្រ/ម$^{៣}$



- ពណ៌សាច់ឈើ : ពណ៌ក្រហមត្នោតស្ទើរតែខ្មៅមានក្រឡាឆ្នូត
- ការប្រើប្រាស់ : គ្រែ តុ ទូ កៅអី ទ្វារ បង្អួច ក្តារក្រាល ក្តារជើ បង្កាន់ដៃជណ្តើរ ក្តារជញ្ជាំងផ្ទះ ស៊ុមទ្វារនិងបង្អួច ការ៉ូក្រាល ពិដាន គ្រឿងបង្កាន់ដៃ គ្រឿងអលង្ការ គ្រឿងតែងលម្អក្នុងផ្ទះ វត្ថុសិល្បៈ ឧបករណ៍ភ្លេង ឧបករណ៍កសិកម្ម គ្រឿងសំណង់ គ្រឿងចម្លាក់ និងប្រើសម្រាប់ការរចនាផ្សេងៗទៀត។

# ២- ក្រញូងស្វា

- ឈ្មោះវិទ្យាសាស្ត្រ : *Dalbergia cultrata* Benth.
- ឈ្មោះពាណិជ្ជកម្ម : Kranhug sva / Burma blackwood
- អំបូរ : Leguminosae
- ចំណាត់ថ្នាក់ : ឈើមិនទាន់ចាត់ថ្នាក់
- ដង់ស៊ីតេ : ១០០០-១២០០ គ.ក្រ/ម៣



- ពណ៌សាច់ឈើ : ពណ៌ត្នោតចាស់មានក្រឡាអង្កាញ់ៗ
- ការប្រើប្រាស់ : គ្រែ តុ ទូ កៅអី ទ្វារ បង្អួច ក្តារក្រាល ក្តារជើ បង្កាន់ដៃជណ្តើរ ក្តារជញ្ជាំងផ្ទះ ស៊ុមទ្វារនិងបង្អួច ការ៉ូក្រាល ពិដាន គ្រឿងបង្កាន់ដៃ គ្រឿងអលង្ការ គ្រឿងតែងលម្អក្នុងផ្ទះ វត្ថុសិល្បៈ ឧបករណ៍ភ្លេង ឧបករណ៍កសិកម្ម គ្រឿងសំណង់ គ្រឿងចម្លាក់ និងប្រើសម្រាប់ការរចនាផ្សេងៗទៀត។

## ៣- គ្រើល

- ឈ្មោះវិទ្យាសាស្ត្រ : *Gluta laccifera* (Pierre) Ding Hou
- ឈ្មោះពាណិជ្ជកម្ម : Kroeul / Rengas / Machang
- អំបូរ : Anacardiaceae
- ចំណាត់ថ្នាក់ : ប្រភេទឈើប្រណិត
- ដង់ស៊ីតេ : ៨០០-១០០០ គ.ក្រ/ម$^{៣}$



- ពណ៌សាច់ឈើ : ពណ៌ម្ទេសទុំមានក្រឡាឆ្នូត
- ការប្រើប្រាស់ : គ្រែ តុ ទូ កៅអី ទ្វារ បង្អួច ក្តារក្រាល កាំជណ្តើរ ក្តារជញ្ជាំងផ្ទះ ស៊ុមទ្វារនិងបង្អួច ការ៉ូក្រាល គ្រឿងបង្កាន់ដៃ គ្រឿងសំណង់ គ្រឿងចម្លាក់ គ្រឿងតែងលម្អក្នុងផ្ទះ វត្ថុសិល្បៈ និងប្រើសម្រាប់ការរចនាផ្សេងៗទៀត។

## ៤- ច្រេស

- ឈ្មោះវិទ្យាសាស្ត្រ : *Albizia lebbeck* (L.) Benth.
- ឈ្មោះពាណិជ្ជកម្ម : Chres / Albizia
- អំបូរ : Leguminosae
- ចំណាត់ថ្នាក់ : ប្រភេទឈើប្រណិត
- ដង់ស៊ីតេ : ៧០០-៩០០ គ.ក្រ/ម³



- ពណ៌សាច់ឈើ : ពណ៌លឿងចាស់
- ការប្រើប្រាស់ : តុ ទូ កៅអី គ្រឿងសង្ហារឹម គ្រឿងចម្លាក់ គ្រឿងតែងលម្អក្នុងផ្ទះ វីនៀរ ផ្លាយវូត វត្ថុសិល្បៈ និងប្រើសម្រាប់ការរចនាផ្សេងៗទៀត។

# ៥- ឈើខ្មៅ

- ឈ្មោះវិទ្យាសាស្ត្រ : *Diospyros pendula* Hasselt ex Hassk.
- ឈ្មោះពាណិជ្ជកម្ម : Chhoeu khmao / Toko phanom / Keau num
- អំបូរ : Ebenaceae
- ចំណាត់ថ្នាក់ : ប្រភេទឈើប្រណិត
- ដង់ស៊ីតេ : ១១០០-១៣០០ គ.ក្រ/ម៣



- ពណ៌សាច់ឈើ : ពណ៌ខ្មៅរលោង
- ការប្រើប្រាស់ : គ្រឿងចម្លាក់ គ្រឿងអលង្ការ គ្រឿងតែងលម្អក្នុងផ្ទះ វត្ថុសិល្បៈ ឧបករណ៍ភ្លេង និងប្រើសម្រាប់ការរចនាផ្សេងៗទៀត។

# ៦- តាត្រាវ

- ឈ្មោះវិទ្យាសាស្ត្រ : *Fagraea fragrans* Roxb.
- ឈ្មោះពាណិជ្ជកម្ម : Tatrao / Tembusu / Anan
- អំបូរ : Gentianaceae
- ចំណាត់ថ្នាក់ : ប្រភេទឈើប្រណិត
- ដង់ស៊ីតេ : ៨០០-១០០០ គ.ក្រ/ម$^{៣}$



- ពណ៌សាច់ឈើ : ពណ៌លឿងទុំមានក្រឡាឆ្នូត
- ការប្រើប្រាស់ : ក្តារជើ្យ ក្តារមឈូស ការ៉ូក្រាល ពិដាន កំណល់ វត្ថុសិល្បៈ គ្រឿងសង្ហារឹម គ្រឿងចម្លាក់ គ្រឿងតែងលម្អក្នុងផ្ទះ សំណង់ក្នុងទីសក្ការៈបូជា និងប្រើសម្រាប់ការរចនាផ្សេងៗទៀត។